**Mekong Watch**
3F Aoki Building 1-12-11 Taito
Taito-ku, Tokyo 110-0016 Japan
E-mail: info@mekongwatch.org
Website: http://www.mekongwatch.org

**3S Rivers Protection Network**
Okantuel Village
Bueng Kanseng Sangkat
Banlung,Ratanakiri,Cambodia
E-mail: info@3spn.org
Website: http://www.3spn.org

# គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ នៅភាគឦសាននៃប្រទេសកម្ពុជា

គម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ (LS2) គឺជាទំនប់មួយដែលនឹងត្រូវសាងសង់នៅលើទន្លេសេសាន ក្នុងស្រុកសេសាន ខេត្តស្ទឹងត្រែង ប្រទេសកម្ពុជា ដែលមានចម្ងាយ១,៥គីឡូម៉ែត្រផ្នែកខាងក្រោមនៃចំនុចប្រសព្វគ្នារវាងទន្លេសេសាននិងទន្លេស្រែពក និងមានចម្ងាយប្រមាណជា២៥គីឡូម៉ែត្រ ពីចំណុចជួបគ្នានឹងទន្លេមេគង្គ។ គម្រោងនេះត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃប្រទេសកម្ពុជា នៅក្នុងខែវិច្ឆិកា ឆ្នាំ២០១២ ហើយការសាងសង់ចាប់ផ្តើមនៅក្នុងខែកុម្ភៈ ឆ្នាំ២០១៤ បើទោះបីជារបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA) ដែលមិនបានឆ្លើយតបទៅនឹងការអនុវត្តន៍ដ៏ល្អប្រសើរជាអន្តរជាតិក៏ដោយ។

តាមលក្ខណៈបច្ចេកទេស ប្រសិនបើទំនប់វារីអគ្គិសនីសេសានក្រោម២ត្រូវបានសាងសង់ក្នុងដៃទន្លេមេ នឹងបង្កឲ្យមានផលប៉ះពាល់យ៉ាងអវិជ្ជមានគួរឲ្យកត់សម្គាល់លើធនធានជលផល និងជីវៈចំរុះនៃអាងទន្លេមេគង្គក្រោម។ ការសិក្សាមួយនៅឆ្នាំ២០១២ (National Academy of Sciences) បានចង្អុលបង្ហាញថា ទំនប់វារីអគ្គិសនីនេះនឹងបណ្តាលអោយមានការធ្លាក់ចុះនូវបរិមាណត្រី ៩,៣% ហើយត្រីចំនួនជាង ៥០ប្រភេទ នឹងប្រឈមនូវការបាត់បង់ផុតពូជ។




*ផែនទីបង្ហាញពីអាងស្តុកទឹកនៃទំនប់វារីអគ្គិសនីសេសានក្រោម២ និងភូមិសំខាន់ៗនៅក្នុងអាងទន្លេ (ប្រភព: វិច្ឆិកា ២០១២)*

អ្នកជំនាញជាច្រើនបានហាមប្រាមចំពោះការសាងសង់ទំនប់មួយនេះ ដែលអាចធ្វើអោយមានការផ្លាស់ប្តូរនូវប្រព័ន្ធជលសាស្ត្ររបស់ទន្លេមេគង្គ និងទន្លេសាប ក៏ដូចជាកាត់បន្ថយនូវលំហូរដីល្បាប់ដែលមានជីជាតិសម្រាប់ដំណាំកសិកម្មប្រមាណពី៦ ទៅ៨%។ ក្នុងចំណោមទំនប់វារីអគ្គិសនីដែលបានគ្រោងសាងសង់នៅតំបន់មេគង្គក្រោមទាំងអស់ ទំនប់វារីអគ្គិសនីសេសានក្រោម២នេះ នឹងបង្កឲ្យមានផលប៉ះពាល់យ៉ាងធំធេងបំផុតលើជីវម៉ាស (ការរស់នៅផ្ដុំគ្នា) របស់ត្រីក្នុងទន្លេ បើធៀបនឹងទំនប់នានាដែលបានគ្រោងនៅក្នុងអាងទន្លេមេគង្គក្រោម។ ផលប៉ះពាល់ទាំងនេះនឹងជះឥទ្ធិពលទៅដល់តំបន់ដីសណ្តទន្លេមេគង្គក្រោមក្នុងប្រទេសវៀតណាម និងផ្នែកខាងលើក្នុងប្រទេសឡាវ និងប្រទេសថៃ។

អ្នកភូមិចំនួនរាប់ពាន់នាក់កំពុងរស់នៅតាមទន្លេមេគង្គក៏ដូចជានៅតាមដៃទន្លេទាំងនេះដែរ នឹងទទួលរងនូវផលប៉ះពាល់អវិជ្ជមានមកលើជីវភាពរស់នៅប្រចាំថ្ងៃ លើសុវត្ថិភាពស្បៀង និងអាយុជីវិតរបស់ពួកគេ ព្រោះតែទំនប់វារីអគ្គិសនីសេសានក្រោម២នេះ។ ដោយការទទួលស្គាល់នូវផលប៉ះពាល់អវិជ្ជមានក្នុងតំបន់ពីទំនប់វារីអគ្គិសនី នៅក្នុងខែមិថុនាឆ្នាំ២០១២ ម្ចាស់ជំនួយអន្តរជាតិជាច្រើនរបស់គណៈកម្មការជាតិទន្លេមេគង្គ(MRC)បានជម្រុញឲ្យរដ្ឋាភិបាលកម្ពុជាធ្វើការគិតគូរ និងរចនាប្លង់គម្រោងឡើងវិញ និងដាក់ជូនមកគណៈកម្មការជាតិទន្លេមេគង្គដើម្បីធ្វើការពិគ្រោះយោបល់។

## ព័ត៌មានពីទំនប់វារីអគ្គិសនីសេសានក្រោម២

**កម្លាំងថាមពលផលិត៖** ៤០០មេហ្គាវ៉ាត់
**កំពស់៖** ប្រហែល ៤០ ម៉ែត្រ
**ប្រវែង៖** ០៨ គីឡូម៉ែត្រ
**ទំហំផ្ទៃអាងស្តុកទឹក៖** ៣៣៥០០ហិកតា
**ចំណាយទុនសាងសង់៖** ៨១៦លានដុល្លាសហរដ្ឋអាមេរិច


ទន្លេសេសានក្នុងភូមិស្រែគរ ២០១៣

ទំនប់វារីអគ្គិសនីសេសានក្រោម២ គឺជាគម្រោងមួយតាមបែបការកសាង-ការប្រតិបត្តិ-ការផ្ទេរ (BOT) ជូនទៅរដ្ឋក្នុងការប្រើប្រាស់ថាមពល អគ្គិសនីទាំងនោះបន្ទាប់ពីផុតកុងត្រារបស់ក្រុមហ៊ុន ។ ការសាងសង់ទំនប់វារីអគ្គិសនីត្រូវចំណាយពេល៥ឆ្នាំ ទើបសាងសង់រួច។ បន្ទាប់ពីដំណើរការបាន៤០ឆ្នាំ នោះក្រុមហ៊ុននឹងផ្ទេរមកឲ្យរដ្ឋាភិបាលកម្ពុជា។ យោងតាមការជូនសេចក្តីប្រកាសរបស់រដ្ឋាភិបាលកម្ពុជាបានឲ្យដឹងថា ថាមពលអគ្គិសនីដែលផលិតបាននឹងលក់ឲ្យទៅអគ្គិសនីកម្ពុជា (EDC) នឹងលក់នាំចេញទៅឲ្យប្រទេស វៀតណាមផងដែរ។

**អ្នកអភិវឌ្ឍន៍គម្រោង៖** ក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២ ខូអិលធីឌី (Hydro Power Lower Sesan 2 Co. Ltd.: HPLS2) គឺជាក្រុមហ៊ុនមួយដែលមានកើតឡើងពីការចូលហ៊ុនគ្នារវាងក្រុមហ៊ុនរ៉ូយ៉ាល់

គ្រុប(៣៩%) និងឆៃណាហាយដ្រូឡានឆាងអ៊ិនធើណាសិនណាល់អ៊ិននើជី (China's Hydrolancang International Energy) ដែលជាក្រុមហ៊ុនបុត្រសម្ព័ន្ធរបស់ក្រុមហ៊ុនហ្វ៊ួននីង (Huaneng Group) របស់ចិន (៥១%) ហើយនឹងអគ្គិសនីវៀតណាមអន្តរជាតិ (EVNI), ដែលជាសាខារបស់ក្រុនហ៊ុនអគ្គិសនីវៀតណាម (EVN)ចំនួន១០%។

**អ្នកផ្តល់ហិរញ្ញប្បទាន៖** ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២ គឺ៣០% ជាទុនរបស់ក្រុមហ៊ុន និង៧០%ទៀតជាកម្ចីបានមកពីធនាគារមួយដែលមិនស្គាល់ឈ្មោះ តែភាគច្រើនគឺបានមកពីប្រទេសចិន។

## ព្រឹត្តការណ៍សំខាន់ៗ

**ខែមិថុនា ឆ្នាំ២០០៧៖** អនុស្សរណៈយោគយល់មួយ (MOU) ត្រូវបានចុះហត្ថលេខារវាងអគ្គិសនីវៀតណាម (EVN) និងក្រសួងឧស្សាហកម្ម រ៉ែ និងថាមពលនៃរដ្ឋាភិបាលកម្ពុជា ឲ្យក្រុមហ៊ុនអគ្គិសនីវៀតណាមធ្វើការសិក្សាពីលទ្ធភាពនៃការសាងសង់ទំនប់។

**ឆ្នាំ២០០៨ - ២០០៩៖** ករណីសិក្សាពីលទ្ធភាពនៃការសាងសង់ទំនប់ត្រូវបានធ្វើឡើងដោយសាខាក្រុមហ៊ុនអគ្គិសនីវៀតណាម គឺភីអ៊ីស៊ីស៊ីមួយ (PECC1)

**ខែមករា ដល់ខែមិថុនា ឆ្នាំ២០០៨៖** ការសិក្សាពីហេតុប៉ះពាល់បរិស្ថាន និងសង្គមត្រូវបានធ្វើឡើងដោយទីប្រឹក្សាកម្ពុជា(KCC)។

**ខែមិថុនា ឆ្នាំ២០១០៖** របាយការណ៍សិក្សាហេតុប៉ះពាល់បរិស្ថានរបស់គម្រោងត្រូវបានអនុម័ត។

**ខែមេសា ឆ្នាំ២០១១៖** ក្រុមហ៊ុនសាងសង់ទំនប់វារីអគ្គិសនីកម្ពុជា វៀតណាមដែលមានភាគហ៊ុនពីក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប៤៩% និងអគ្គិសនីវៀតណាមអន្តរជាតិ (EVNI)៥១% ត្រូវបង្កើតនិងទទួលស្គាល់ថាជាអ្នកអភិវឌ្ឍទំនប់វារីអគ្គិសនីមួយនេះ។ ក្រោយមកបានចុះបញ្ជីជាផ្លូវការថា ក្រុមហ៊ុនទំនប់វារី អគ្គិសនីសេសានក្រោម២ ខូអិលធីឌី (HPLS2) ក្នុងឆ្នាំ២០១១ ដោយក្រុមហ៊ុនរ៉ូ យ៉ាល់គ្រុប។

**ខែវិច្ឆិកា ឆ្នាំ២០១២៖** ទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានអនុម័តដោយគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជា។ កិច្ចព្រមព្រៀងសាងសង់ត្រូវបានចុះហត្ថលេខារវាងក្រុមហ៊ុនរ៉ូយ៉ាល់គ្រុប និងក្រុមហ៊ុនហាយដ្រូឡានឆាងអ៊ិនធើណាសិនណាល់អ៊ិននើជី(Hydrolancang Internal Energy)។

**ខែកុម្ភៈ ឆ្នាំ២០១៣៖** ច្បាប់របស់រដ្ឋាភិបាលកម្ពុជាអំពីការទូទាត់សំណងលើគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ត្រូវបានអនុម័តដោយរដ្ឋសភាជាតិ។

**ខែមីនា ឆ្នាំ២០១៣៖** កាសែតសារព័ត៌មានក្នុងស្រុកមួយបានចេញផ្សាយថា អាង &អាសូស៊ីអេសិនឡោយើ ខូអិលធីឌី (Ang & Associate Lawer Co. ltd.) គឺជាក្រុមហ៊ុនដែលជាកម្មសិទ្ធិរបស់អ្នកឧកញ្ញា

គិត ម៉េង និងដែលបានកំពុងតែសំអាតផ្ទៃអាងស្តុកទឹករបស់ទំនប់វារីអគ្គិសនី។

**ខែមករា ឆ្នាំ២០១៤៖** បទបញ្ញានិងនីតិវិធីច្បាប់សម្រាប់ដោះស្រាយគោលនយោបាយសំណង និងការតាំងទីលំនៅថ្មីត្រូវបានអនុម័តដោយក្រសួងរ៉ែ និងថាមពល (ពីមុនគឺក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល ប្តូរមកជាក្រសួង រ៉ែ និងថាមពល) ។ គោលនយោបាយដំណោះស្រាយសំណងសម្រាប់ផលប៉ះពាល់នៃគម្រោងទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានរៀបចំដោយក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២ អិលធីឌី។

**ខែកុម្ភៈ ឆ្នាំ២០១៤** ៖ ការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២បានចាប់ផ្តើម។

**ខែមិនា ឆ្នាំ២០១៤៖** គណៈកម្មាធិការសម្រាប់អនុវត្តន៍ការដោះស្រាយផលប៉ះពាល់នៃទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានបង្កើតឡើង និងអនុម័តដោយអភិបាលខេត្តស្ទឹងត្រែង។

**ខែមិថុនា ដល់ ខែសីហា ឆ្នាំ២០១៤៖** គណៈកម្មាធិការដោះស្រាយនិងសំណងបានរៀបចំកិច្ចប្រជុំតាមភូមិដែលរងផលប៉ះពាល់នីមួយៗ ដើម្បីបង្ហាញគោលការណ៍សំណងដល់អ្នកភូមិ។ អ្នកភូមិជាច្រើនមិនបានយល់ស្របជាមួយនឹងគោលនយោបាយសំណងនោះ ហើយបានអះអាងថា អត្រាសំណងនោះគឺមិនគ្រប់គ្រាន់ និងសមរម្យទេ។

**ខែកក្កដា ឆ្នាំ២០១៤៖** ទទួលបានព័ត៌មានឲ្យដឹងថា ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងត្រូវធ្វើការរចនាប្លង់សារជាថ្មីឡើងវិញដោយមានការផ្លាស់ប្តូរនូវរចនាសម្ព័ន្ធ និងកំពស់នៃជញ្ជាំងទំនប់វារីអគ្គិសនី។

**ខែវិច្ឆិកា ឆ្នាំ២០១៤៖ ការសិក្សាពីទ្រព្យសម្បត្តិបានចាប់ផ្តើមសម្រាប់ដើម្បីគណនាប្រាក់សំណង** គ្រួសារសហគមន៍។

**ខែមិនា ឆ្នាំ ២០១៥៖** គណៈកម្មាធិបរិស្ថាននៃរដ្ឋសភាជាតិកម្ពុជាបានធ្វើដំណើរទស្សនកិច្ច និងស៊ើបអង្កេតមួយទៅតំបន់ការដ្ឋានសង់សាង់ទំនប់ និងភូមិស្រែគ ដែលនឹងត្រូវបានជន់លិចដោយសារទំនប់វារីអគ្គិសនីសេសានក្រោម២។

**ខែមេសា ឆ្នាំ២០១៥៖** ការសាងសង់កន្លែងតាំងទីលំនៅថ្មីសម្រាប់ឃុំក្បាលរមាសបានចាប់ផ្តើម។ ដីភូមិថ្មីនោះ មានទីតាំងស្ថិតនៅតាមបណ្តោយផ្លូវជាតិលេខ ៧៨ និងប្រហែលជា ២០ គីឡូម៉ែត្រ ពីភូមិចាស់បច្ចុប្បន្នរបស់ពួកគេ។

**ខែមេសា ឆ្នាំ២០១៥៖** កន្លែងតាំងទីលំនៅថ្មីសម្រាប់ឃុំក្បាលរមាសបានចាប់ផ្តើម ដែលមានទីតាំងនៅតាមបណ្តោយផ្លូវជាតិលេខ ៧៨ និងមានចម្ងាយ៤៨៩ - ៤៩១គីឡូម៉ែត្រ ពីរាជធានីភ្នំពេញ។

**ខែមិថុនា ឆ្នាំ២០១៥៖** គណៈកម្មការសំណង និងរើតាំងទីលំនៅថ្មី បានបញ្ជូនលិខិតជូនដំណឹងជាផ្លូវការទៅមេឃុំក្បាលរមាស និងមេភូមិច្រប់ និងមេភូមិស្រែស្រណុក ពីដំណើរការនៃការរើតាំងលំនៅថ្មី។

**ខែកក្កដា ឆ្នាំ២០១៥៖** ក្រុមតំណាង HPLS2 មួយក្រុម និងអភិបាលខេត្តស្ទឹងត្រែង បានទៅទស្សនាភូមិច្រប់ និងភូមិស្រែស្រណុក ដើម្បីជម្រុញដល់ការតាំងទីលំនៅថ្មី។ ភាគច្រើននៃអ្នកភូមិច្រប់ និងអ្នកភូមិ

ស្រែស្រណុក បានចាប់ផ្លាស់ប្តូរចេញពីភូមិចាស់របស់ខ្លួន។

**ខែកក្កដា ឆ្នាំ២០១៥៖** វេទិកាសាធារណៈស្តីពីទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវបានធ្វើឡើងនៅក្រុងស្ទឹងត្រែង។ អ្នកភូមិដែលរងផលប៉ះពាល់ប្រមាណជា១០០នាក់ បានទៅមើលការដ្ឋានសាងសង់ទំនប់វារីអគ្គិសនី និងកន្លែងតាំងទីលំនៅថ្មីនៅបណ្តោយផ្លូវជាតិលេខ៧៨។ អ្នកភូមិបានពន្យល់ ពីបញ្ហានៃដំណើរការផ្តល់សំណង និងតាំងលំនៅថ្មី ព្រមទាំងបានធ្វើសំណើទៅតំណាងក្រុមហ៊ុន (HPLS2), រដ្ឋលេខាធិការនៃក្រសួងរ៉ែ និងថាមពល និងអភិបាលខេត្តស្ទឹងត្រែង ដើម្បីផ្តល់នូវការធានាសម្រាប់ផ្ទះសំបែង, និង បញ្ឈប់ការសាងសង់របស់ខ្លួន ហើយធ្វើការស្រាវជ្រាវពីផលប៉ះពាល់នៅខ្សែទឹកខាងលើនៃទំនប់នេះ។

## ផលប៉ះពាល់បរិស្ថាន និងសង្គមមកលើសហគមន៍កម្ពុជា និងសហគមន៍ក្នុងតំបន់

ទំនប់វារីអគ្គិសនីសេសានក្រោម២ (LS2) មានទីតាំងស្ថិតនៅដីរាប ឬតំបន់ទំនាប និងមានកំពស់ ៤0ម៉ែត្រ និងមានផ្ទៃដីអាងផ្ទុកទឹកទំហំ ៣៣៥00ហិកតា ។ យោងតាមរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន (EIA)គម្រោងនេះនឹងធ្វើឲ្យប្រជាជនចំនួន៤៧៨៥នាក់ ជម្លៀសចេញពីភូមិឋានទៅតាំងទីលំនៅថ្មី ក្នុងនោះមាន១០៥៩គ្រួសារមកពីភូមិចំនួន ៧ នៅក្នុងឃុំចំនួន៤។ របាយការណ៍មួយដែលបានបោះពុម្ពផ្សាយនៅក្នុងឆ្នាំ២០០៩បានបង្ហាញថា ផលប៉ះពាល់ទៅដល់ផ្នែកខាងលើនៃទំនប់នេះ អាចនឹងមានសភាពធ្ងន់ធ្ងរជាងការប៉ាន់ប្រមាណនៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានទៅទៀត (EIA) ហើយយ៉ាងហោចណាស់មានប្រជាជនចំនួន៧៨០០០នាក់ នៅតាមដងទន្លេសេសាន និងទន្លេស្រែពក នៅផ្នែកខាងលើនៃទំនប់វារីអគ្គិសនីសេសានក្រោម២ (LS2) ក៏ដូចជាភូមិចំនួន៨៧ភូមិ នៅតាមដងទន្លេពីរនេះ (សេសាន ស្រែពក) នឹងត្រូវបាត់បង់លទ្ធភាពសម្រាប់ចរាចរត្រីឡើងចុះក្នុងទន្លេទាំងនេះ។ ករណីសិក្សាមួយចំនួនទៀតក៏បានរកឃើញផងដែរថា ប្រជាជនជាង២២០០០នាក់ ដែលកំពុងរស់នៅផ្នែកខាងក្រោមទន្លេពីទំនប់វារីអគ្គិសនីសេសានក្រោម២ (LS2) នឹងទទួលរងនូវផលប៉ះពាល់ជាអវិជ្ជមានដោយសារការផ្លាស់ប្តូរនូវជលវិទ្យា និងគុណភាពទឹក ។ ផ្ទុយទៅវិញ នៅក្នុងច្បាប់ថ្មីមួយបានអនុម័តដោយរាជរដ្ឋាភិបាលកម្ពុជានៅក្នុងឆ្នាំ២០១៣នេះ បែជាបង្ហាញថា ផលប៉ះពាល់ទូទៅរបស់ទំនប់វារីអគ្គិសនីមួយនេះ មានតិចតួចទៅវិញ ដោយបានអះអាងថាមានប្រជាជនតិចជាង៨00 គ្រួសារនៅក្នុងឃុំចំនួនបី នឹងត្រូវបានធ្វើការផ្លាស់ប្តូររើទីលំនៅថ្មី នឹងត្រូវទទួលបានសំណងពីការខូចខាត។

នៅក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានបានសរសេរថា ទីតាំងថ្មីចំនួន៦កន្លែង ត្រូវបានគ្រោងបម្រុងទុកសម្រាប់ការផ្លាស់ប្តូរទីលំនៅថ្មីជូនដល់សហគមន៍មូលដ្ឋាន។ បើយោងតាមសម្តីរបស់អ្នកភូមិដែលត្រូវរើតាំងទីលំនៅថ្មីបានបញ្ជាក់ថា តំបន់ថ្មីទាំងនោះ គឺស្ថិតនៅក្នុងតំបន់ព្រៃការពារ ឬតំបន់ដីសម្បទានរបស់ក្រុមហ៊ុន។ រាជរដ្ឋាភិបាលកម្ពុជាបានរៀបចំទីតាំងលំនៅដ្ឋានថ្មី ប៉ុន្តែមានក្តីបារម្ភយ៉ាងខ្លាំងអំពីទីតាំងថ្មីនោះ គឺឋិតនៅឆ្ងាយពេកពីភូមិរបស់ពួកគាត់នាពេលបច្ចុប្បន្ន និងមិនអាចអំណោយផលដល់ការប្រកបរបរកសិកម្ម ដូចជាដំណាំស្រូវ និងបន្លែជាដើម។

## លទ្ធភាពសេដ្ឋកិច្ច

អ្នកជំនាញរបស់រាជរដ្ឋាភិបាលកម្ពុជារំពឹងថា នឹងរកប្រាក់ចំណូលពីការបង់ពន្ធពីទំនប់វារីអគ្គិសនីសេសានក្រោម២ចំនួន២៩,៥លានដុល្លារសហរដ្ឋអាមេរិចក្នុងមួយឆ្នាំនៅពេលទំនប់ចាប់ផ្តើមដំណើរការ។ ទោះជាយ៉ាងណាក៏ដោយ ក៏នៅមានការចោទជាសំនួរចំពោះលទ្ធភាពសេដ្ឋកិច្ចពីទំនប់វារីអគ្គិសនីនេះជាពិសេស នេះជាសញ្ញាមួយដែលធ្វើឲ្យការប្រែប្រួលអាកាសធាតុមានការកើនឡើង ដែលរួមបញ្ចូលទាំងគ្រោះរាំងស្ងួត និងផ្លាស់ប្តូរនូវលំហូរទឹកតាំងមានដំណើរការនៃទំនប់វារីអគ្គិសនីនៅផ្នែកខាងលើ ។ នៅលើដងទន្លេសេសាន គឺបានសាងសង់ទំនប់វារីអគ្គិសនីជាច្រើនរួចមកហើយនៅផ្នែកខាងលើក្នុងប្រទេសវៀតណាម ហើយទំនប់ទាំងនេះ ក៏បានជួបនូវវិបត្តិក្នុងការផ្គត់ផ្គង់ថាមពលអគ្គិសនីពុំគ្រប់គ្រាន់ផងដែរ។ ជាលទ្ធផល មានន័យថា ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងបង្កឲ្យមានកង្វះខាតលំហូរទឹក និងមិនអាចផលិតបានថាមពលអគ្គិសនីតាមការគ្រោងទុកដល់ទៅ៤០០ម៉េហ្គាវ៉ាត់នោះទេ។ ជាការពិតណាស់ នៅក្នុងរបាយការណ៍សិក្សាពីហេតុប៉ះពាល់បរិស្ថាន និង សង្គមបានប៉ាន់ប្រមាណថាការផលិតថាមពលអគ្គិសនីរបស់ទំនប់វារីអគ្គិសនីសេសានក្រោម២ នឹងមានការធ្លាក់ចុះដល់១០០ម៉េហ្គាវ៉ាត់នៅរដូវប្រាំង តែស្របពេលគ្នានេះ ប្រទេសកម្ពុជាមានតម្រូវការថាមពលខ្ពស់ជាងនេះទៅទៀត។

## កង្វះខាតនូវការពិគ្រោះយោបល់



ភូមិស្រែគរ ២០១៣

សហគមន៍រងផលប៉ះពាល់មិនត្រូវបានពិគ្រោះយោបល់ជាមួយពួកគេអោយបានសមរម្យនោះទេ ក៏ដូចជាមិនបានផ្តល់ព័ត៌មានអោយបានគ្រប់គ្រាន់ដល់ពួកគេដែរ ទាំងផលប៉ះពាល់អវិជ្ជមានរបស់ទំនប់វារីអគ្គិសនីសេសានក្រោម២ ឬផែនការរើតាំងទីលំនៅថ្មី និងសំណងជាដើម។ សហគមន៍ដែលរស់នៅផ្នែកខាងក្រោមនៃទំនប់វារីអគ្គិសនីសេសានក្រោម២ មិនបានទទួលការពិគ្រោះយោបល់ជាមួយពួកគេអំពីបញ្ហាសំណង និងការតាំងទំលំនៅថ្មីនោះទេក្នុងពេលធ្វើសេចក្តីសម្រេចចិត្តនោះ។ ពួកគេត្រូវបានជូនដំណឹងតបន្ទាប់ពីផែនការ និងគោលនយោបាយពាក់ព័ន្ធនានាត្រូវបាន។ សហគមន៍មិនត្រូវបានគេផ្តល់ឱកាសណាមួយសម្រាប់ការពិភាក្សានោះទេ។

ខែវិច្ឆិកា ២០១២ និងខែកុម្ភៈ ២០១៣ អាជ្ញាធរមូលដ្ឋានបានរៀបចំការប្រជុំមួយនៅថ្នាក់ភូមិដែលស្ថិតនៅទីតាំងអាងស្តុកទឹកនៃទំនប់វារីអគ្គិសនីសេសានក្រោម២។ យោងតាមសម្តីសហគមន៍ដែលបានចូលរួមក្នុងកិច្ចប្រជុំអាជ្ញាធរបានត្រៀមជម្រើសទីតាំងសម្រាប់ការតាំងទីលំនៅថ្មី រួមមានទីតាមដែលបិតនៅតាមដងទន្លេសេកុង និងពន្យល់ថាសំណងនឹងត្រូវបានផ្តល់ជូនដោយមានបញ្ចូលទាំងដីសម្រាប់សង់លំនៅដ្ឋាន និងដីកសិកម្ម។ ទោះបីជាបែបនេះក្តី សហគមន៍បានត្អូញត្អែរថា ព័ត៌មាននេះពុំទាន់មានភាពច្បាស់ និងមិនអាចជឿទុកចិត្តនៅឡើយទេ ពីព្រោះនៅមិនទាន់មានសេចក្តីលំអិត និង លិខិតស្នាមជាលាយលក្ខអក្សរជាក់លាក់ណាមួយត្រូវបាន ផ្តល់ជូនមកដល់សហគមន៍មូលដ្ឋាននៅឡើយ។

នៅក្នុងខែមករាឆ្នាំ ២០១៤ គោលនយោបាយសំណង និងការតាំងទីលំនៅថ្មី ត្រូវបានអនុម័តដោយក្រសួងរ៉ែ និងថាមពល។ ទោះជាយ៉ាងណាក៏ដោយ មានតែអាជ្ញាធរមូលដ្ឋាន និងមេឃុំប៉ុណ្ណោះ

ដែលត្រូវបានគេផ្តល់ឱ្យនូវឯកសារដែលពាក់ព័ន្ធតែមួយច្បាប់គត់ ហើយឯកសារទាំងនេះត្រូវបានផ្តល់ជូនដោយគ្មានការពន្យល់គ្រប់គ្រាន់លើខ្លឹមសាររបស់វានោះទេ។ ក្នុងខែមិថុនា និងខែកក្កដា គណៈកម្មាធិការអនុវត្តន៍គោលនយោបាយសំណង និងការតាំងទីលំនៅថ្មី បានរៀបចំកិច្ចប្រជុំផ្សព្វផ្សាយពីគោលនយោបាយនេះទៅដល់ភូមិដែលរងផលប៉ះពាល់។ ឯកសារគោលនយោបាយនេះត្រូវបានប្រគល់ទៅឱ្យអ្នកចូលរួមគ្នា ប៉ុន្តែពួកគេត្រូវបានប្រាប់ថា គោលនយោបាយនេះ គឺមិនអាចធ្វើការកែប្រែ ឬផ្លាស់ប្តូរបានទេ។

ដោយយោងតាមបទពិសោធន៍ផ្សេងៗគ្នាពីការទទួលរងនូវផលប៉ះពាល់របស់អ្នករស់នៅនៅផ្នែកខាងក្រោមពីទំនប់វារីអគ្គិសនីនៅប្រទេសវៀតណាមអស់ជាងមួយទស្សវត្សហើយនោះ ធ្វើឲ្យសហគមន៍ដែលរស់នៅតាមដងទន្លេសេសាន និងស្រែពកបានជំទាស់ទៅនឹងការសាងសង់ទំនប់វារីអគ្គិសនីសេសានក្រោម២អស់រយៈពេលជាង៥ឆ្នាំមកហើយ ដែលសហគមន៍បានស្នើអោយម្ចាស់គម្រោង និងរាជរដ្ឋាភិបាលកម្ពុជា អោយមានរៀបចំកិច្ចប្រជុំពិភាក្សាពីបញ្ហាដែលពុំទាន់បានដោះស្រាយ និងពិចារណាទៅលើជំរើសថាមពលដែលមាននិរន្តរភាព ដើម្បីអោយសមទៅនឹងតម្រូវការអគ្គិសនីរបស់ប្រទេស។

## អនុសាសន៍

1) អ្នកអភិវឌ្ឍន៍គម្រោង និងរាជរដ្ឋាភិបាលកម្ពុជាគួរតែទទួលស្គាល់ពីផលប៉ះពាល់ដ៏ធ្ងន់ធ្ងរនៃទំនប់វារីអគ្គិសនីសេសានក្រោម២ ទៅលើធនធានធម្មជាតិនៃទន្លេមេគង្គ ជាពិសេសមច្ឆាជាតិ និងជីវភាពរស់នៅប្រចាំថ្ងៃ ព្រមទាំងសុវត្ថិភាពស្បៀងរបស់សហគមន៍មូលដ្ឋាន មិនត្រឹមតែនៅក្នុងប្រទេសកម្ពុជានោះទេ ប៉ុន្តែប្រជាជនជាច្រើនទៀតតាមអាងទន្លេមេគង្គទាំងអស់ ក៏នឹងត្រូវទទួលរងនូវផលប៉ះពាល់នេះដែរ និងសូមអោយមានការពិចារណាឡើងវិញទៅលើគម្រោងមួយនេះ ។

2) គណៈកម្មាការទន្លេមេគង្គ(MRC) និងរាជរដ្ឋាភិបាលកម្ពុជា គួរតែទទួលស្គាល់នូវផលប៉ះពាល់អវិជ្ជមានផ្សេងៗជាច្រើន ទៅលើអាងទន្លេមេគង្គទាំងមូល ហើយសូមពិចារណាលើគម្រោងដោយពុំគួរចាត់ទុកថា វាគ្រាន់តែជាទំនប់វារីអគ្គិសនីនៅតាមដៃទន្លេ តែត្រូវគិតថា វាក៏ជាទំនប់វារីអគ្គិសនីមួយដែលសមមូលទៅនឹងទំនប់វារីអគ្គិសនីមួយដែលសាងសង់លើដងទន្លេមេគង្គដែរ ហើយគួរយកបញ្ហានេះដាក់បញ្ចូលទៅក្នុងដំណើរការនៃកិច្ចប្រជុំពិគ្រោះយោបល់របស់គណៈកម្មការទន្លេមេគង្គ។

3) ផលប៉ះពាល់អវិជ្ជមាននៃទំនប់វារីអគ្គិសនីសេសានក្រោម២មកលើបរិស្ថានវិទ្យា ក៏ដូចជាជីវិតរស់នៅតាមដងទន្លេមេគង្គ ជីវភាពរស់នៅប្រចាំថ្ងៃ និងវប្បធម៌ប្រពៃណីរបស់សហគមន៍មូលដ្ឋាន ជាពិសេសសហគមន៍ជនជាតិដើមភាគតិច ដែលពឹងផ្អែកលើធនធានធម្មជាតិដែលមានក្នុង និងតាមដងទន្លេ គួរតែសិក្សាអោយបានហ្មត់ចត់ និងថ្លឹងថ្លែងអំពីចំណូលសេដ្ឋកិច្ចដែលយើងទទួលបានពីគម្រោងនេះ។ ការសិក្សាទាំងនេះមិនគួរធ្វើការសិក្សាតែនៅក្នុងប្រទេសកម្ពុជាប៉ុណ្ណោះទេ តែគួរធ្វើការសិក្សាដោយគ្របដណ្តប់ទៅដល់តំបន់នៃអាងទន្លេមេគង្គទាំងមូលផងដែរ។

4) ក្រុមហ៊ុនទំនប់វារីអគ្គិសនីសេសានក្រោម២ និង រាជរដ្ឋាភិបាលកម្ពុជា គួរតែផ្សព្វផ្សាយជាសាធារណៈ នូវរបាយការណ៍ដែលថា ទំនប់វារីអគ្គិសនីសេសានក្រោម២ ត្រូវរចនាប្លង់សារជាថ្មី និងសិក្សាពីហេតុប៉ះពាល់បរិស្ថានឡើងវិញ។ ការសិក្សាពីហេតុប៉ះពាល់បរិស្ថានថ្មី គួរតែពង្រីកវិសាលភាពនៃការវាយតម្លៃពីផលប៉ះពាល់របស់ទំនប់វារីអគ្គិសនីសេសានក្រោម២ ទៅដល់អាង

ទន្លេមេគង្គ។ សកម្មភាពសាងសង់ទាំងអស់ដែលទាក់ទងទៅនឹងទំនប់វារីអគ្គិសនីនេះ គួរតែផ្អាកសិន រហូតដល់របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានថ្មីត្រូវបានបញ្ចប់។

5) ព័ត៌មានស្តីពីទំនប់វារីអគ្គិសនីសេសានក្រោម២ និងផែនការផ្លាស់ប្តូទីលំនៅថ្មី និងផែនការសំណងគួរតែត្រូវបានចែកចាយ និងជូនដំណឹងដល់សហគមន៍ដែលនឹងទទួលរងនូវផលប៉ះពាល់ពីគម្រោងដោយផ្ទាល់ក្តី និង ដោយប្រយោលក្តី។ ពួកគាត់គួរតែចូលរួមពិគ្រោះយោបល់អោយបានពេញលេញ ហើយគំនិតយោបល់របស់ពួកគាត់គួរតែត្រូវបានដាក់បញ្ចូលនៅក្នុងការធ្វើសេចក្តីសម្រេចចិត្តចុងក្រោយ ។

## **យោង៖**


Baird, Ian G. 2009. *Best Practices in Compensation and Resettlement for Large Dams: The Case of the Planned Lower Sesan 2 Hydropower Project in Northeastern Cambodia*. Phnom Penh, Cambodia: Rivers Coalition Cambodia.

Cambodia Daily. "Government Approves Dam on Lower Sesan," November 5, 2012. http://www.cambodiadaily.com/news/government-approves-dam-on-lower-sesan-5159/

----------. "Electricity Vietnam No Longer Involved in Lower Sesan 2 Dam," November 28, 2012. http://www.cambodiadaily.com/news/electricity-vietnam-no-longer-involved-in-lower-sesan-2-dam-6363/

Global Times. "Cambodian, Chinese Firms to Jointly Develop Hydropower Plant," November 26, 2012. http://www.globaltimes.cn/content/746551.shtml

Grimsditch, Marc. 2012. *3S Rivers Under Threat.* 3S Rivers Protection Network and International Rivers.

International Rivers. "Cambodia's Lower Sesan 2 Dam's Draft Law Evades Costs and Concerns," Accessed on July 11, 2013. http://www.internationalrivers.org/resources/cambodia%E2%80%99s-lower-sesan-2-dam%E2%80%99s-draft-law-evades-costs-and-concerns-7825

----------. "Lower Sesan 2 Dam," Accessed on September 1, 2015. http://www.internationalrivers.org/campaigns/lower-sesan-2-dam

International Water Power & Dam Construction. "China's Huaneng takes majority stake in Se San River Ⅱ hydro project, Cambodia," February 24 2014. http://www.waterpowermagazine.com/news/newschinas-huaneng-takes-majority-stake-in-se-san-river-ii-hydro-project-cambodia-4183165

Phnom Penh Post. "Lies, Threats at Dam Site," April 8, 2013. http://www.phnompenhpost.com/national/lies-threats-dam-site

PECC1 & KCC. 2008. *Environmental Impact Assessment for Feasibility Study of Lower Sesan 2 Hydropower Project, Stung Treng Province, Cambodia.* Phnom Penh, Cambodia

Vicheka S. 2012. *Lower Sesan 2 Hydropower Dam: Current Livelihoods of Local Communities (A Baseline Study).* Phnom Penh, Cambodia: The NGO Forum of Cambodia.

Mekong Watch. *Interview at Affected Village in February 2015 Regarding Asset Measurement Survey Held on Lower Sesan 2 Dam*, June 15, 2015. http://www.mekongwatch.org/PDF/LS2_FieldNoteRegardingAssetSurvey.pdf

----------. *Lower Sesan 2 Dam Compensation and Resettlement Program Implementation Impacts on Indigenous Communities (Notes made from interviews in July 2015)*, November 5, 2015. http://www.mekongwatch.org/PDF/LS2_NotesCompensationResettlement.pdf

Ziv, G., Baran, E., Nam, S., Rodríguez-Iturbe, I., and Levin, S. 2012. "Trading-off Fish Biodiversity, Food Security and Hydropower in the Mekong River Basin," *Proceedings of the National Academy of Sciences of the United States of America*. http://www.pnas.org/content/109/15/5609.full.pdf+html


*(ព័ត៌មានទាំងអស់ខាងលើបានធ្វើបច្ចុប្បន្នភាពនៅថ្ងៃទី ១០ ខែវិច្ឆិកា ឆ្នាំ២០១៥)*